# ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
# វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

## អនុសាសន៍ក្លូនកៅស៊ូនៅកម្ពុជាសម្រាប់ឆ្នាំ២០២៣ - ២០២៥

### សេចក្ដីផ្ដើម

ក្លូនកៅស៊ូដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍដំណាំកៅស៊ូនៅប្រទេសកម្ពុជា។ចម្ការពិសោធន៍ក្លូនជាច្រើនត្រូវបានវិទ្យាស្ថានស្រាវជ្រាវកៅស៊ូ កម្ពុជារៀបចំបង្កើតឡើងជាបន្តបន្ទាប់ដើម្បីវាយតម្លៃពីសក្ដានុពលនៃក្លូនកៅស៊ូនីមួយៗ។បណ្ដាទិន្នន័យដែលបានមកពីចម្ការពិសោធន៍ទាំងនោះត្រូវបានយកមកប្រើប្រាស់ក្នុងការរៀបចំអនុសាសន៍ក្លូនកៅស៊ូនៅកម្ពុជាសម្រាប់ឆ្នាំ២០២៣-២០២៥។ អនុសាសន៍នេះត្រូវបានធ្វើបច្ចុប្បន្នភាពរៀងរាល់៣-៥ឆ្នាំម្ដង។


RRIM600


RRIM712


IRCA130


PB217


PB280


RRIC121


GT1

### ១. អនុសាសន៍ក្លូនសម្រាប់ចម្ការកៅស៊ូកសិឧស្សាហកម្ម

| ថ្នាក់១ | ថ្នាក់២ | ថ្នាក់៣ |
|---|---|---|
| RRIM 600 | GT 1 | IRCA 41 |
| RRIM 712 | IRCA 230 | IRCA 109 |
| IRCA 130 | KV 4 | IRCA 317 |
| PB 217 | PB 235 | IRCA 331 |
| PB 280 | PB 314 | PB 310 |
| | PB 254 | PB 324 |
| | PR 303 | PB 330 |
| | RRIC 100 | PR 255 |
| | RRIC 101 | PR 300 |
| | RRIC 121 | PR 306 |







**ថ្នាក់១៖** ជាបណ្ដាក្លូនដែលមានទិន្នផលខ្ពស់ និងមាន លក្ខណៈក្សេត្រសាស្ត្រល្អ ដោយបានដាំសាកល្បងនៅក្នុងចម្ការពិសោធន៍ក្លូនទ្រង់ទ្រាយធំ ហើយត្រូវបានសិក្សាលើទិន្នន័យផ្សេងៗ រួមទាំងការប្រមូលផលរយៈពេលយ៉ាងតិច៧ឆ្នាំ។ ក្លូនទាំងនេះជារួមមានពី៣ទៅ៥ក្លូន ដែលគេគប្បីដាំនៅលើផ្ទៃដីពី៥០ទៅ៥៥%នៃផ្ទៃដីគ្រោងដាំកូន កៅស៊ូប្រចាំឆ្នាំ ដោយដាំក្លូននីមួយៗ ពី១៥ទៅ២០%។

**ថ្នាក់២៖** ជាបណ្ដាក្លូនដែលមានទិន្នផលខ្ពស់មានលក្ខណៈ ក្សេត្រសាស្ត្រល្អ (ចម្ការពិសោធន៍ក្លូនទ្រង់ទ្រាយធំ) ប៉ុន្តែ មានទិន្នន័យតិចតួច។ គេគប្បីដាំក្លូនទាំងនេះនៅលើផ្ទៃដី៤០% នៃផ្ទៃដីគ្រោងដាំកូនកៅស៊ូប្រចាំឆ្នាំ ដោយដាំក្លូននីមួយៗប្រមាណ១០%។

**ថ្នាក់៣៖** រាប់បញ្ចូលនូវក្លូនទាំងឡាយដែលគេបានដាំជា លក្ខណៈពិសោធន៍ទ្រង់ទ្រាយតូច ហើយគេសង្កេតឃើញថា ក្លូននោះផ្តល់ទិន្នផលខ្ពស់ មានលក្ខណៈក្សេត្រសាស្ត្រល្អ ប៉ុន្តែគេនៅមិនទាន់មានទិន្នន័យគ្រប់គ្រាន់នៅឡើយ ហើយ គេគប្បីដាំបណ្ដាក្លូនទាំងនោះឱ្យបានច្រើនជាលក្ខណៈពិពិធកម្មនៅក្នុងចម្ការ។ ក្លូនទាំងនេះគប្បីដាំនៅលើផ្ទៃដីពី១ទៅ៥% នៃផ្ទៃដីគ្រោងដាំប្រចាំឆ្នាំ ឬដាំវាជាម៉ូណូក្លូន (ក្លូនតែមួយ) នៅលើផ្ទៃដីប្រមាណពី ៥ ទៅ ១០ហិកតា។







### ២. អនុសាសន៍ក្លូនសម្រាប់ចម្ការកៅស៊ូគ្រួសារ

| ក្លូន | ទិន្នផល | ការលូតលាស់ | ភាពធន់ នឹងខ្យល់ | ភាពធន់នឹងបម្រែបម្រួលបរិយាកាស |
|---|---|---|---|---|
| RRIM 600 | ខ្ពស់ | មធ្យម | ខ្ពស់ | ខ្ពស់ |
| RRIM 712 | ខ្ពស់ | មធ្យម | ខ្ពស់ | មធ្យម |
| PB 280 | ខ្ពស់ | ខ្ពស់ | មធ្យម | បង្គួរ |
| RRIC 100 | បង្គួរ | ខ្ពស់ | ខ្ពស់ | មធ្យម |

1. បើផ្ទៃដីតិចជាង៥ហិកតា គួរជ្រើសរើស១ក្លូនសម្រាប់ដាំដុះ
2.បើផ្ទៃដី៥-១០ហិកតា គួរជ្រើសរើស១ ឬ២ក្លូនសម្រាប់ដាំដុះ
3.បើផ្ទៃដី១០-២០ ហិកតា គួរជ្រើសរើស២ ឬ៣ក្លូនសម្រាប់ដាំដុះ
4. បើផ្ទៃដីធំជាង ២០ ហិកតា គួរជ្រើសរើស៣ ឬ៤ក្លូនសម្រាប់ដាំដុះ